ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១២៤៥ សហវ.ប្រ.

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រថ្នាក់ទី១ ទី២ និងថ្នាក់ទី៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួល មាត្រា ៨៤ មាត្រា៨៥ និងមាត្រា៨៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

Scanned by CamScanner

- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រដែលជួបការលំបាក នៅបឋមសិក្សារៀនថ្នាក់ទី១ ទី២ និងថ្នាក់ទី៣។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ ដូចខាងក្រោម៖

- កំណត់អំពីការផ្តល់អាហារូបករណ៍
- កំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់អាហារូបករណ៍។

**ប្រការ៣ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់អាហារូបករណ៍សិស្សក្រីក្រ ដែលជួបការលំបាក នៅថ្នាក់ទី១ ទី២ និងថ្នាក់ទី៣ តាមគ្រឹះស្ថានសិក្សាសាធារណៈ។

**ជំពូកទី២**

**ការផ្តល់ លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាហារូបករណ៍**

**ប្រការ៤.-**

អាហារូបករណ៍ ត្រូវផ្តល់ក្នុងមួយឆ្នាំសិក្សាដល់សិស្សក្រីក្រដែលជួបការលំបាក នៅថ្នាក់ទី១ ទី២ និងថ្នាក់ទី៣ ក្នុងម្នាក់ៗ ២៤០ ០០០រៀល (ពីររយសែសិបពាន់រៀល) ចាប់ពីឆ្នាំសិក្សា ២០១៨-២០១៩ នេះតទៅ។

**ប្រការ៥.-**

លក្ខខណ្ឌលម្អិតនៃការផ្តល់អាហារូបករណ៍ នីតិវិធីនៃការផ្តល់អាហារូបករណ៍ គណៈកម្មការជ្រើសរើសអាហារូបករណ៍ តួនាទី និងភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មការ ត្រូវអនុវត្តតាមប្រកាសលេខ ២៤៥៧ អយក.ប្រក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការកំណត់លក្ខខណ្ឌ និងនីតិធីនៃការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ។

**ជំពូកទី៣**

**អន្តរប្បញ្ញត្តិ**



Scanned by CamScanner

**ប្រការ៦ .-**

ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៣ សម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ ត្រូវអនុវត្តចំនួនប្រាំពីរខេត្តគឺ ខេត្តកោះកុង ក្រចេះ មណ្ឌលគិរី ឧត្តរមានជ័យ ប៉ៃលិន ព្រះវិហារ និងខេត្តត្បូងឃ្មុំ។

វិសាលភាពការផ្តល់អាហារូបករណ៍នេះ ទៅរាជធានី ខេត្តដទៃទៀត ត្រូវអនុវត្តចាប់ពីឆ្នាំសិក្សា ២០១៩-២០២០ ស្របតាមស្ថានភាពហិរញ្ញវត្ថុ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨ .-**

គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣ កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**កន្លែងទទួល៖**

- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -អាជ្ញាធរសេវនកម្មជាតិ

"ដើម្បីជូនជ្រាប"

- -ដូចប្រការ៨ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ



Scanned by CamScanner